ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០៤

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

Work Activities

ប្រចាំខែ មេសា ឆ្នាំ ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការវាយតម្លៃទីក្រុងស្អាត | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិសម្រាប់មនុស្សចាស់កម្ពុជា | ៣ |
| ៣- | សេចក្តីព្រាងរបាយការណ៍ស្តីពី ការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ | ៤ |
| ៤- | សេចក្តីព្រាងអនុក្រឹត្យស្តីពី របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ | ៦ |
| ៥- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១១ | ៧ |
| ៦- | សកម្មភាពដ៏ទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបង្កើតគណៈកម្មាធិការវាយតម្លៃទីក្រុងស្អាត

កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ប៉ា អង់តូនី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការវាយតម្លៃទីក្រុងស្អាត ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងទេសចរណ៍ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ដោយអនុវត្តអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងក្នុងឱកាសពិធីបិទសន្និបាតបូកសរុបសភាពការណ៍អនុវត្តការងារទេសចរណ៍ កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ក្នុងការជំរុញយុទ្ធនាការផ្សព្វផ្សាយ " កម្ពុជា ៖ ព្រះរាជាណាចក្រ អច្ឆរិយៈ " និងចលនាប្រលងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ ពិសេសឯកភាពឱ្យក្រសួងទេសចរណ៍ រៀបចំជាការប្រលងប្រណាំងទីក្រុងស្អាត ក្នុងគោលបំណងលើកកម្ពស់សោភណភាព អនាម័យ បរិស្ថានល្អនៅតាមបណ្តាទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍ សហការជាមួយអង្គការ " Acting for life " និងសាកលវិទ្យាល័យទូលូស៍ ប្រទេសបារាំង បានរៀបចំបងក្រង " ឯកសារស្តង់ដាទីក្រុងស្អាត " ដើម្បីធ្វើកិច្ចការនេះ ក្រុមការងារបានជ្រើសរើសទីក្រុងជាគោលដៅទេសចរណ៍មួយចំនួនសម្រាប់ធ្វើអង្កេត និងកសាងសូចនាករ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការវាយតម្លៃក្នុងការប្រលងប្រណាំងនេះ។



ក្រុមការងារបានចុះអង្កេត សិក្សា និងពិនិត្យផ្ទាល់ជាមួយអាជ្ញាធរមូលដ្ឋាន ផ្នែកពាក់ព័ន្ធ ប្រតិបត្តិករ ផ្នែកឯកជន និងប្រជាពលរដ្ឋនៅតាមទីក្រុង និងគោលដៅទេសចរណ៍សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា។

ខ្លឹមសារគោលរបស់ឯកសារស្តង់ដាទីក្រុងស្អាត ដែលប្រមូលផ្តុំនូវប្រធានបទធំៗចំនួន ៧ រួមមាន សូចនាករនៃការគ្រប់គ្រងបរិស្ថាន សូចនាករនៃភាពស្អាត សូចនាករនៃការគ្រប់គ្រងសំណល់រឹងនិងរាវ សូចនាករស្តីពីព័ត៌មាន និងការបញ្ជ្រាបការយល់ដឹង សូចនាករនៃតំបន់បៃតង សូចនាករ



សន្តិសុខទីក្រុងនិងសុវត្ថិភាពសុខាភិបាល សូចនាករនៃហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍។ ប្រធានបទទាំងនេះប្រមូលផ្តុំនូវសូចនាករសរុបចំនួន ៣០ និងលក្ខណៈវិនិច្ឆ័យចំនួន ៦១ សម្រាប់វាយតម្លៃនិងធ្វើការសម្រេចផ្តល់ជ័យលាភីជូនទីក្រុងជាបេក្ខភាពដោយផ្តោតជាសំខាន់ទៅលើចំណុចមួយចំនួនដូចជា ភាពស្អាត ការគ្រប់គ្រងសំណល់ និងការបញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីបរិស្ថានជាដើម(១)។

ដើម្បីជំរុញការអនុវត្តឯកសារស្តង់ដាទីក្រុងស្អាតនេះឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាព ក្រសួងទេសចរណ៍ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ក្នុងគោលបំណងដើម្បីពិនិត្យតាមដានជាប្រចាំ និងធ្វើការវាយតម្លៃទីក្រុងស្អាតរៀងរាល់២ឆ្នាំម្តង។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការវាយតម្លៃទីក្រុងស្អាត ។

សេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# ការបង្កើតគណៈកម្មាធិការជាតិ សម្រាប់មនុស្សចាស់កម្ពុជា

កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០ នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសន** អនុ-ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ប៉ា អង់ធូនី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់មនុស្សចាស់កម្ពុជា** ដោយមានការអញ្ជើញចូលរួមប្រជុំពីសំណាក់តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិកអគ្គលេខាធិការរង និង មន្ត្រីនៃក.ស.វ. សមាជិក និង មន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់លើសុខុមាលភាពមនុស្សចាស់។ ដោយអនុលោមតាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការអភិវឌ្ឍសង្គមនៃអង្គការសហប្រជាជាតិ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំទិវាមនុស្សចាស់ នៅរៀងរាល់ថ្ងៃទី១ ខែតុលា រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ លេខ៤០ អនក្រ.បក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិនិងជួយជនចាស់ជរា ដោយកំណត់យកថ្ងៃទី១ ខែតុលា ជាទិវាមនុស្សចាស់អន្តរជាតិ។

ស្ថានភាពមនុស្សចាស់កម្ពុជាបច្ចុប្បន្ននេះកាន់តែមានការរីកចម្រើន អត្រាមនុស្សចាស់ដែលមានអាយុចាប់ពី ៦៥ឆ្នាំឡើងទៅមាន ៦% ហើយអាចកើនឡើងជាបន្តបន្ទាប់ អាស្រ័យដោយសុខុមាលភាពសង្គមកាន់តែប្រសើរឡើង។

ដោយពិនិត្យឃើញថា អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិនិងជួយជនចាស់ជរា មានចំណុចមួយចំនួនមិនសមស្រប ហើយចាំបាច់ត្រូវកែសម្រួល ដូចជាការកំណត់យកថ្ងៃទី១ ខែតុលា ជាទិវាមនុស្សចាស់កម្ពុជា រួមជាមួយនឹងទិវាមនុស្សចាស់អន្តរជាតិ និងឈ្មោះស្ថាប័នជាដើម(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងនេះ ហើយបានយល់ឃើញថា ទម្រង់ និងខ្លឹមសាររបស់សេចក្ដីព្រាងអនុក្រឹត្យនេះមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ តាមទម្រង់ដែលបានប្រើចំពោះអនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការឬអង្គភាពនានា នាពេលបច្ចុប្បន្ន ដូច្នេះ អង្គប្រជុំជំនាញបច្ចេកទេសបានសម្រេចបង្កើតក្រុមការងារមួយ មានសមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងក្រសួងសាមី ដើម្បីជួយពិនិត្យកែសម្រួលទម្រង់និងខ្លឹមសារនៃសេចក្ដីព្រាងនេះឡើងវិញ សម្រាប់កិច្ចប្រជុំបច្ចេកទេសនៅពេលក្រោយ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្ដីព្រាងឯកសារនេះ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុស្ដីពី សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់មនុស្សចាស់កម្ពុជា។

## សេចក្តីព្រាងរបាយការណ៍ស្តីពី

# ការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារនៅក្នុង ជម្លោះប្រដាប់អាវុធ

កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:00 នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឡេង សៃ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុង **ជម្លោះប្រដាប់អាវុធ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពី "ការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ" នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ និង "ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ" នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២។

យោងមាត្រា៨ ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និង រូបភាពអាសអាភាសកុមារ រយៈពេល២ឆ្នាំបន្ទាប់ពីការផ្តល់សច្ចាប័ន (ឆ្នាំ២០០២) ប្រទេសកម្ពុជាមានកាតព្វកិច្ចធ្វើរបាយការណ៍លើកដំបូងស្តីពីការអនុវត្តពិធីសារខាងលើជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិនិងបន្ទាប់មករៀងរាល់៥ឆ្នាំម្តង។ របាយការណ៍នេះជារបាយការណ៍លើកទី១ និងលើកទី២បញ្ចូលគ្នា សម្រាប់រយៈពេល ២០០២-២០១០។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពី "ការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ " ដោយផ្អែកតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិឆ្នាំ២០០៧(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍នេះ ហើយសមាជិកអង្គប្រជុំខ្លះ បានស្នើសុំពិនិត្យកម្រងសំណួរឬសេចក្តីណែនាំដែលគណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិដាក់ជូនសាមីក្រសួង ដើម្បីផ្ទៀងផ្ទាត់ខ្លឹមសាររបាយការណ៍នៃការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញានេះ។ ឆ្លើយតបនឹងការស្នើសុំនេះ អង្គប្រជុំស្នើឲ្យសាមីក្រសួងដែលជាសមត្ថកិច្ចទទួលខុសត្រូវរៀបចំរបាយការណ៍នេះ ពន្យល់កម្រងសំណួរឬសេចក្តីណែនាំ សម្រាប់ចំណុចនីមួយៗជូនអង្គប្រជុំ ដើម្បីអង្គប្រជុំរួមយោបល់កែលម្អខ្លឹមសារ នីតិវិធីនៃកិច្ចប្រជុំជំនាញបច្ចេកទេសដែលធ្លាប់អនុវត្តកន្លងមក។

អង្គប្រជុំបានបន្តពិភាក្សា ហើយបានសម្រេចកែសម្រួល ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ សេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ត្រឹមចំណុច១៩ នឹងបន្តនៅថ្ងៃក្រោយ៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុង ជម្លោះប្រដាប់អាវុធ។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# របបគោលនយោបាយចំពោះជនពិការក្រីក្រ នៅតាមសហគមន៍



កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញ បច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **នាង ស៊ីថុន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក អគ្គលេខាធិការរង និង មន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

សូមរំឮកថា សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការនិងគ្រួសារក្រីក្រងាយរងគ្រោះនៅតាមសហគមន៍ បានឆ្លងកិច្ចប្រជុំតាមនីតិវិធីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងបានដាក់ឆ្លងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ អនុសាសន៍របស់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ពីព្រោះមានច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ មាត្រា១២និងមាត្រា ១៩ ចង្អុលហើយ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងកែសម្រួលថ្មីគឺ សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ហើយបានសម្រេចកែសម្រួល ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ បន្ថែមទៀតដើម្បីឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង ៕



# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
# ប្រចាំខែមីនា ឆ្នាំ២០១១



កាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១១ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានរៀបចំកិច្ចប្រជុំទូលាយមួយ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែមីនា ឆ្នាំ២០១១** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ ក្នុងខែមីនានេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង០៧.% ធៀបនឹងខែមុន និងកើនឡើង៣.៨% បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល ១២ខែ)។ ក្នុងកំណើនសន្ទស្សន៍ថ្លៃ **មីនា|កុម្ភៈ** មានការរួមចំណែកពីក្រុមម្ហូបអាហារ ៤៦ % ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត ៩ % ការដឹកជញ្ជូន ២៧% និងភោជនីយដ្ឋាន ៤%។

➡ គួរកត់សម្គាល់ថា ថ្លៃសាំង និងម៉ាស៊ូត មានការកើនឡើងគួរឲ្យបារម្ភ។ ក្នុងអំលុង ៣ខែដើមឆ្នាំ២០១១ ថ្លៃសាំងកើន ១៤% និងថ្លៃម៉ាស៊ូតកើន ២១% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១០ (តារាង១ កុលោន %Δ*)។

➡ ក្រុមទំនិញសំខាន់ៗ បើប្រៀបធៀបខែ(មីនា/កុម្ភៈ) បង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

*(ក្នុងវង់ក្រចក៖ បម្រែបម្រួលរយៈពេល ១២ខែ)*

- ម្ហូបអាហារៈ +0.៧% ( +៤.១% )
- សម្លៀកបំពាក់ និងស្បែកជើងៈ +១.២% ( +១.៣%)
- ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈ +0.៣% ( +៣.0%)
- ការដឹកជញ្ជូនៈ +១.៥% ( +៥.១%)
- ភោជនីយដ្ឋានៈ +0.៥% ( +៦.៣%)
- ទំនិញ និងសេវាកម្មផ្សេងទៀតៈ +១.២% ( +៨.៧%)

➡ តារាងខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ក្នុងអំលុង ៣ឆ្នាំចុងក្រោយ។

| ឆ្នាំ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ ធៀបនឹង... | ខែដូចគ្នាឆ្នាំមុន | ៣.៣% | ៣.៨% | ៣.៨% | | | | | | | | | | |
| | ខែមុន | 0.២% | 0.៧% | 0.៧% | | | | | | | | | | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦.៩% | ៧.៣% | ៦.៧% | ៥.៣% | ៤.៥% | ២.៥% | ១.៦% | ១.៧% | ១.៩% | ៣.៦% | ៣.២% | ៧.៣% | ៤% |
| | ខែមុន | 0% | 0.៣% | 0.៦% | -0.៣% | 0.២% | 0% | 0.៥% | 0.៩% | 0.៧% | ១.៤% | –១.0% | –0.២% | |
| ២00៩ | ខែដូចគ្នាឆ្នាំមុន | ៨.0% | ៦.២% | -0.៧% | -៣.៩% | -៥.៧% | -៤.៨% | -៣.៩% | -២.៩% | -២.៣% | -១.៥% | ១.៣% | ៨.0% | -0.៧% |
| | ខែមុន | -១.៥% | -0.១% | ១.៣% | ១.0% | ១.0% | ១.៩% | ១.៤% | 0.៧% | 0.៥% | -0.៣% | -0.៦% | -0.១% | |

* ការវិភាគជាលាយលក្ខណ៍អក្សរជាការដកស្រង់ចេញពីទិន្នន័យចំបងៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះអ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្ដីត្រូវការរៀងខ្លួន។

➡រូបខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០—២០១១ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




➡ គោលនយោបាយរូបិយវត្ថុរបស់ ធនាគារជាតិនៃកម្ពុជា មានគោលដៅរក្សាស្ថេរភាពថ្លៃ ដោយយកអត្រាប្តូរប្រាក់ ៛/ដុល្លារ ជាឧបករណ៍។ ដូច្នេះហើយ យើងសង្កេតឃើញថាអត្រាប្តូរប្រាក់ **៛/ដុល្លារ** មានកម្រិតថេរជុំវិញ ៤,០០០៛។ ដោយឡែក ក្នុងខែមីនា ឆ្នាំ២០១១ មានអត្រាស្មើនឹង ៤,០០៥ ៛/១ដុល្លារ ។

➡ អត្រាប្តូរប្រាក់ **៛/បាត** ស្មើនឹង **១៣២៛/១បាត** បើធៀបនឹងខែមុន ស្ថិតនៅថេរ ប៉ុន្តែប្រាក់រៀលចុះថោក ២.៣% ធៀបនឹងបាត ក្នុងរយៈពេល ១២ខែ។

➡ អត្រាប្តូរប្រាក់ **៛/ដុង** ស្មើនឹង **០.១៩២៛/១ដុង** បើធៀបនឹងខែមុន ប្រាក់រៀលឡើងថ្លៃ ០.៥% និងឡើងថ្លៃ ១២.៣% ធៀបនឹងដុង ក្នុងរយៈពេល ១២ខែ។

➡ អត្រាប្តូរប្រាក់ **ដុង/ដុល្លារ** និង**បាត/ដុល្លារ** បង្ហាញថា ក្នុងរយៈពេល១២ខែ (មីនា២០១០—មីនា២០១១) បាតថៃឡើងថ្លៃ ៦.២% ឯដុងវៀតណាម ចុះថោក ៩.៤% ធៀបនឹងដុល្លារ។

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ **នាខែមីនា ឆ្នាំ២០១១នេះថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

↳ ***ចំណូលអនុវត្តបានចំនួន ៥៨១.៨ ពាន់លានរៀល*** *(មធ្យមប្រចាំខែអនុវត្តបាន ៨៧% នៃគម្រោង) ក្នុងនោះ* ***ចំណូល មូលធន ១១.៧ ពាន់លានរៀល*** *(មធ្យមប្រចាំខែអនុវត្តបាន ១០៨% នៃគម្រោង) និង****ចំណូលចរន្ត ៥៧០.១ ពាន់លានរៀល*** *(មធ្យមប្រចាំខែអនុវត្តបាន ៨៥% នៃគម្រោង)។*

↳ បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ**កើនឡើង ១២% ប៉ុន្តែ ថយចុះ ១៣% ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណូលក្នុងខែនេះ ជាចម្បងបណ្តាលមកពីចំណូលចរន្តកើនឡើង ៣៤%។ គួរចាប់អារម្មណ៍ថា ចំណូលចរន្តថយចុះ ៦.១% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។




↳ ឯចំណូលមូលធន ថយចុះ ៨៨% បើធៀបនឹងខែមុន និងថយចុះ៨១% ក្នុងរយៈពេល ១២ខែ។

↳ ក្នុងចំណូលចរន្ត:
- ✓ ចំណូលសារពើពន្ធកើនឡើង ២៧% និងកើនឡើង ២.៩% ក្នុងរយៈពេល១២ខែ
- ✓ ចំណូលមិនមែនសារពើពន្ធកើនឡើង៦៨% ប៉ុន្តែថយចុះ ២៨% ក្នុងរយៈពេល១២ខែ

| **ក្នុងចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក : បម្រែបម្រួលរយៈពេល១២ខែ) | | **ក្នុងចំណូលមិនមែនសារពើពន្ធ** (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល១២ខែ) | |
|---|---|---|---|
| ✓ ពន្ធ និងអាករគយ : +២០% | (+៧.៨%) | ✓ នេសាទ : +៩៤% | (+៦១%) |
| ✓ ចំណូលពន្ធដារ : +៣០% | (+១.៨%) | ✓ រុក្ខាប្រមាញ់ : -៦៥% | (-៦៩%) |
| ✓ ចំណូលសារពើពន្ធផ្សេងៗ : -៤៥% | (+២០%) | ✓សម្បទានរ៉ែ : +១៨% | (-៩៩%) |
| | | ✓ អាកាសចរណ៍ស៊ីវិល : -៩១% | (-៥២%) |
| | | ✓ ផលទុនទេសចរណ៍ : -៤៦% | (-៣៦%) |
| | | ✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +៥៧% | (-២៦%) |
| | | ✓ ឯកជនភាវូបនីយកម្ម : កើនគំហុក | (កើនគំហុក) |
| | | ✓ ការលក់អចលនកម្ម : -៧៨% | (-៩០%) |

➢ ***ចំណាយថវិកាជាតិ*** អនុវត្តបាន ៤៥៥.៨ ពាន់លានរៀល (*មធ្យមប្រចាំខែអនុវត្តបាន ៤៥% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត** ៣៩៨.៧ ពាន់លានរៀល ស្មើនឹង ៨៧% នៃចំណាយសរុប (*មធ្យមប្រចាំខែអនុវត្តបាន ៧២% នៃគម្រោង*) និង**ចំណាយមូលធន** ៥៧.១ ពាន់លានរៀល ស្មើនឹង ១៣% នៃចំណាយសរុប (*មធ្យមប្រចាំខែអនុវត្តបាន ១២% នៃគម្រោង*) ។

➢ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ**កើនឡើង ៩% ប៉ុន្តែ ថយចុះ ១០% ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណាយថវិកាជាតិក្នុងខែនេះ គឺបណ្តាលមកពីចំណាយចរន្តកើនឡើង ៦% (រយៈពេល ១២ខែ: +៦%) និងចំណាយមូលធន*កើនឡើង ២៩%* (រយៈពេល ១២ខែ: -៥៧%) ។

➢ ***តុល្យភាពថវិកាជាតិក្នុងខែមីនានេះមានអតិរេកចំនួន ១២៦ ពាន់លានរៀល*** ។ នេះជាអតិរេកថវិកាជាតិ៣ខែជាប់គ្នា ក្នុងឆ្នាំ២០១១។

## ៣) ស្ថានភាពរូបិយវត្ថុ និងអត្រាការប្រាក់

➡ ក្នុងខែមីនា ឆ្នាំ២០១១ ស្ថានភាពរូបិយវត្ថុមានលក្ខណៈដូចខាងក្រោម៖

➢ ***រូបិយវត្ថុ*** $M_2$ មានចំនួន ***២០,២៧៨ ពាន់លានរៀល*** កើនឡើង ២.១% ធៀបនឹងខែមុន និងកើនឡើង ១៧.៧% ក្នុងរយៈពេល ១២ខែ។ កំណើន $M_2$ បើប្រៀបធៀប**មីនា/កុម្ភៈ** បណ្តាលមកពីរូបិយវត្ថុ $M_1$ កើនឡើង ៤.៥% (រយៈពេល ១២ខែ: +១១.១%) និងរូបិយវត្ថុផ្សេងៗ កើនឡើង ១.៦% (រយៈពេល ១២ខែ: +១៩.១%)។

**(ក្នុងវង់ក្រចក៖ បម្រែបម្រួលរយៈពេល ១២ខែ)**

| | | |
|---|---|---|
| **$M_2$** +២.១% (+១៧.៧%) | **$M_1$** +៤.៥% (+១១.១%) | ✓ រូបិយវត្ថុក្រៅធនាគារ: +៦.៣% (+១១.៧%)<br>✓ ប្រាក់បញ្ញើចរន្ត: –៣០.៣% (–៥.៣%) |
| = $M_1$ + Quasi-money | **រូបិយវត្ថុផ្សេងៗ (Quasi-money)** +១.៦% (+១៩.១%) | ✓ ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ: –១១.១% (+១៨.៥%)<br>✓ ប្រាក់បញ្ញើជារូបិយបណ្ណ: +១.៩% (+១៩.១%) |

➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន២,៦៩៨លានដុល្លារ *កើនឡើង ១.៥%* ធៀបនឹងខែមុន និងកើនឡើង ១៥.៤% ក្នុងរយៈពេល ១២ខែ។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** មានចំនួន ៧,០០១ ពាន់លានរៀល ថយចុះ ១.៨% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៨.៥% ក្នុងរយៈពេល ១២ខែ។

➢ ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** ជារួមមានការកើនឡើង ដោយឡែកក្នុងខែមីនានេះមានចំនួន ១៣,៨៤១ ពាន់លានរៀល កើនឡើង ១.៥% បើធៀបនឹងខែមុន និងកើនឡើង ២៤.៧% ក្នុងរយៈពេល ១២ខែ។

➢ ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** មានចំនួន ១,៨៩៤ ពាន់លានរៀល កើនឡើង ០.៩% បើធៀបនឹងខែមុន និងកើនឡើង ៤៤.៨% ក្នុងរយៈពេល ១២ខែ។

➢ ***អត្រាការប្រាក់ប្រចាំឆ្នាំ*** :(ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល១២ខែ)

| ប្រភេទអត្រាការប្រាក់ | អត្រា | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦.៥៣% | –០.២% | +៤.៥% |
| ▪ កម្ចីជារៀលនៅធនាគារពាណិជ្ជ | ២២.៥៣% | +០.៤% | –១.៨% |
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤.៣៦% | –០.២% | –១២% |
| ▪ កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៥.៩១% | –០.៣% | –១.៩ |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែមីនា ឆ្នាំ២០១១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

↳ កសិកម្ម៖

✓ ផលិតកម្មនេសាទមាន **៣៧.៩ ពាន់តោន** ថយចុះ ២៤% បើធៀបនឹងខែមុន និងថយចុះ ៣% ក្នុងរយៈពេល ១២ខែ។

↳ ឧស្សាហកម្ម៖

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២០៧.៣ លានដុល្លារ (ពី២០៧រោងចក្រ) ថយចុះ ២២% ប៉ុន្តែកើនឡើង ១% ក្នុងរយៈពេល ១២ខែ។

✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២១៤ លានគីឡូវ៉ាត់ម៉ោង កើនឡើង ១០% បើធៀបនឹងខែមុន និង កើនឡើង ១៤% ក្នុងរយៈពេល ១២ខែ។

– អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ០.៨ លានគីឡូវ៉ាត់ម៉ោង ថយចុះ ៤៦% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៥៧% ក្នុងរយៈពេល ១២ខែ។

✓ ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស៖

| ប្រភេទ | ចំនួន—មីនា២០១១ | ចំនួន—កុម្ភៈ២០១១ | ចំនួន—មីនា២០១០ |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៨ | ១០ | ៤ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ៤៦ | ២៦ | ១២ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៦ | ១២ | ២៣ |

➡ សំណង់៖

↳ **សំណង់អនុញ្ញាតឲ្យសាងសង់** មានចំនួន ៣៧១.៤ ពាន់ម² កើនឡើង៣៦% បើធៀបនឹងខែមុន និង កើនឡើង ២៥៦% ក្នុងរយៈពេល១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ១២៧.៣ លានដុល្លារ កើនឡើង ៤៩% បើធៀបនឹងខែមុន និងកើនឡើង ៣២៦% ក្នុងរយៈពេល១២ខែ។

↳ **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះគឺ **លំនៅឋាន** (៦៦%នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និងឧស្សាហកម្ម (២០%នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

| ប្រភេទ | ផ្ទៃក្រឡា ពាន់ម² —មីនា២០១១ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ លំនៅឋាន | ២៤៦ | +៧៩% | +៣៩៨% |
| ▪ ឧស្សាហកម្ម | ៧៤ | +៦៨% | +១១៥ |

➡ វិនិយោគ៖

↳ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./គ.អ.ក. (ថ្មី និងពង្រីក) ក្នុងខែមីនាមានចំនួន៦ តែក្នុងវិស័យឧស្សាហកម្មប៉ុណ្ណោះ។ បើគិតជាទុនវិនិយោគស្មើនឹង **៥០ លានដុល្លារ** កើនឡើង ១១៥% បើធៀបនឹងខែមុន ប៉ុន្តែ ថយចុះ ៥២% ក្នុងរយៈពេល១២ខែ។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន **១៥ ពាន់នាក់**។

➡ សេវាកម្ម និងទេសចរណ៍៖

↳ **ការចុះបញ្ជី និងលុបចេញពីបញ្ជី**

| ប្រភេទ | ចំនួន—មីនា២០១១ | ចំនួន—កុម្ភៈ២០១១ | ចំនួន—មីនា២០១០ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៩៥ | ២៣០ | ២១៦ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២០ | ៦ | ០ |
| ▪ ក្រុមហ៊ុនដែលបានចុះបង់ពន្ធដារតាមរបបពិត | ២៥៣ | ២៤៦ | ២១១ |

**ទំនិញឆ្លងកាត់តាមផែ** (សរុប៦ផែ) មានចំនួន ៤០៦.១ ពាន់តោន កើនឡើង ២៧% ធៀបនឹងខែមុន និង កើនឡើង ១៦% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល១២ខែ | | | |
|---|---|---|---|
| ▪ ផែភ្នំពេញ : +៤០% | (+២១%) | ▪ ផែឧកញ៉ាម៉ុង : +១៧% | ( -១០%) |
| ▪ ផែកំពង់សោម : +២៦% | ( +១៧%) | ▪ ផែស្រែអំបិល និងកោះកុង : -៥៦% | (-៥០%) |

### ការហោះហើរតាមផ្លូវអាកាស និងទេសចរណ៍

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៩.៩ | −២៦% | −២% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៩០.៧ | −១១% | −៦% |
| ▪ ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស | ៤៨ | +១៣% | +៣៣% |
| ▪ ចំនួនអ្នកទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ២៤៨ | −៣% | +៩% |
| ✓ តាមផ្លូវអាកាស | ១៣០ | −១០% | +៦% |
| ✓ តាមផ្លូវគោក និងទឹក | ១១៨ | +៧% | +២៤% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែមីនា មានចំនួន ២,០៤២ ពាន់លានរៀល កើនឡើង២១% បើធៀបនឹងខែមុន និងកើនឡើង ៣៨% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ទំនិញដែលការនាំចូលកើនឡើង មីនា/កុម្ភៈ (ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល១២ខែ) | | | |
|---|---|---|---|
| - ប្រេងឥន្ធនៈ : +១០% | ( +១%) | - រថយន្តសរុប (ពាន់លានរៀល) : +៤៣.៥% | ( +២០%) |
| - ឧស្ម័ន : +១១% | ( -៧%) | - ត្រាក់ទ័រនិងគោយន្ត : +១៤.៩% | ( +៤៤%) |
| - អគ្គិសនី : +១៦% | ( +២៣%) | - ម៉ូតូ : +០.៥% | ( -១៥%) |
| - ដែកសំណង់ : +២០២% | ( +២៨%) | - ស្រូវសាលី : +៣១.០% | ( +៣២%) |
| - ស៊ីម៉ង់ : +២៤% | ( -៣%) | - ផ្លែឈើនិងបន្លែ : +៤៤.៤% | ( +១១%) |
| - គ្រឿងអេឡិចត្រូនិច : +៤៣% | (ស្ថិរ) | - ជីនិងថ្នាំកសិកម្ម : +១៤.៤% | ( +៦៨%) |
| | | - នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ : +៥៧.៥% | ( +៤៦%) |

| ទំនិញដែលការនាំចូលថយចុះ មីនា/កុម្ភៈ (ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល១២ខែ) | | | |
|---|---|---|---|
| - អង្ករ : -១៦.១% | ( +៧%) | -ស្ករស : -៥៦% | ( -៤៣%) |
| -បារី : -២៧.៤% | ( -៤៧%) | -ភេសជ្ជៈ : -៥២% | ( -៤៣%) |

➡ **ការនាំចេញ** ក្នុងខែមីនា ឆ្នាំ២០១១ មានចំនួន ១,៣៣៥.៨ ពាន់លានរៀល កើនឡើង ៤% ធៀបនឹងខែមុន និងកើនឡើង ៤៩% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល១២ខែ | | | |
|---|---|---|---|
| ▪ ផលិតផលឈើកែច្នៃ : +៦៤៩% | (+២៧២%) | ▪ ផលិតផលនេសាទ : −៦៧% | (+៦៤%) |
| ▪ វាយនភណ្ឌនិងស្បែកជើង : +៣% | ( +៤២% ) | ▪ កៅស៊ូ : -៦០% | (+៦១%) |
| ▪ អង្ករ : +១២៣% | (+៣៩៩% ) | | |

➡ *ក្នុងខែមីនា ឆ្នាំ២០១១នេះ ជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ៧០៦ ពាន់លានរៀល ស្មើនឹង ១៧៦ លានដុល្លារ ស.រ.អ.។*

## ៦. កំណត់សម្គាល់សំខាន់ៗ

### ៦.១. ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១) នាខែមីនា ២០១១ សឹងតែគ្រប់មុខទំនិញមានការឡើងថ្លៃ ដោយសារតម្រូវការក្នុងស្រុកកើនឡើងដែលជារដូវកាល និងការឡើងថ្លៃទំនិញក្នុងប្រទេសដែលកម្ពុជានាំចូល។ អត្រាអតិផរណា បើប្រៀបធៀបខែមីនាដូចគ្នា ២០១១/១០ ស្មើនឹង ៣.៨%។

➢ ក្នុងខែមីនា ឆ្នាំ២០១១ សេដ្ឋកិច្ចវៀតណាមមានអតិផរណា ១៣.៩%* បើប្រៀបធៀបសន្ទស្សន៍ថ្លៃប្រើប្រាស់ខែមីនាដូចគ្នា ឆ្នាំ២០១១/១០។ សម្រាប់សេដ្ឋកិច្ចថៃវិញ សូចនាករនេះស្មើនឹង ៣.១%*។

➢ អតិផរណាក្នុងប្រទេសជិតខាង ជះឥទ្ធិពលលើការឡើងថ្លៃមុខទំនិញមួយចំនួននៅកម្ពុជា ដូចជា ម្ហូបអាហារ (សាច់ បន្លែ ផ្លែឈើ ម្ហូបអាហារកែច្នៃ...) សម្លៀកបំពាក់ និងស្បែកជើង ភោជនីយដ្ឋាន និងទំនិញប្រើប្រាស់ផ្សេងៗ ។ល។

២) វិស័យសំណង់ហាក់ដូចជាមានការងើបឡើងវិញ ជាពិសេសសំណង់លំនៅឋាន (សង់ដោយក្រុមហ៊ុន) និងសំណង់ ឧស្សាហកម្ម ។ ប៉ុន្តែការសុំសាងសង់លំនៅឋានជាលក្ខណៈបុគ្គលខ្នាតតូចមានការថយចុះ។

៣) ការនាំចេញផលិតផលឈើកែច្នៃ មាននិន្នាការកើនឡើងគួរឲ្យចាប់អារម្មណ៍

*ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖*

១) សេដ្ឋកិច្ចកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើការនាំចូល ក្នុងនោះប្រហែលជាង ៤០% នៃតម្លៃនាំចូលសរុប គឺជាទំនិញមូលធនសម្រាប់ការវិនិយោគ និងប្រហែលជិត ៥០% ទៀតជាទំនិញប្រើប្រាស់។

២) រីឯការនាំចេញវិញ មួយផ្នែកធំ (ប្រហែល ៩០%) ជាប្រភេទផលិតផលវាយនភណ្ឌនិងស្បែកជើង និងទំនិញកែច្នៃដទៃទៀតដែលម្ចាស់ផលិតកម្មជាវិនិយោគិនបរទេស ចំណែកឯការនាំចេញប្រហែល ១០% ទៀត ជាប្រភេទវត្ថុធាតុដើម ដូចជាកៅស៊ូ ផលិតផលឈើ និងផលិតផលសត្វ។

៣) ការកាត់បន្ថយការពឹងផ្អែកលើការនាំចូល ដើរតួជាយុទ្ធសាស្ត្រសំខាន់ក្នុងរយៈពេលវែង តាមរយៈការជំរុញ និងកសាងមូលដ្ឋានផ្គត់ផ្គង់ក្នុងស្រុក។ ការបង្កើនលទ្ធភាពផ្គត់ផ្គង់ខ្លួនឯង ក៏ជាមធ្យោបាយដែលអាចជួយបង្ការបានមួយកំរិតនូវការរងឥទ្ធិពលអាក្រក់ពីវិបត្តក្រៅប្រទេស ដូចជាការឡើងថ្លៃទំនិញ ការឡើងចុះអត្រាប្តូរប្រាក់ និងកលិយុគហិរញ្ញវត្ថុជាដើម ជាពិសេស នៅក្នុងប្រទេសដែលមានទំនាក់ទំនងសេដ្ឋកិច្ច–ពាណិជ្ជកម្មជាមួយព្រះរាជាណាចក្រកម្ពុជា។

### ៦.២. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមីនា ឆ្នាំ២០១១នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | ធៀបនឹងខែមុន | រយៈពេល១២ខែ | ផ្សេងៗ |
|---|---|---|---|
| ១. ថ្លៃប្រេងសាំង<br>ម៉ាស៊ូត<br>ឧស្ម័ន | +២.១%<br>+៣.៦%<br>+១.៥% | +១៣%<br>+២២%<br>+១៦% | — |
| ២. បំណុលមិនមែនសារពើពន្ធ | +៦៨% | -២៨% | — |
| ៣. ផលទុននៃសកម្មភាពទេសចរណ៍ (មិនមែនសារពើពន្ធ) | -៤៦% | -៣៦% | — |
| ៤.សំណង់អនុញ្ញាតឲ្យសាងសង់ (ពាន់ម៉²) | +៣៦% | +២៥៦% | — |
| ៥. គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក. (ទុនវិនិយោគ) | -៥២% | -៩៣% | លំហូរទុនវិនិយោគអនុញ្ញាត ដោយ គ.វ.ក./ក.អ.ក. នាខែនេះមានតែក្នុងវិស័យឧស្សាហកម្មប៉ុណ្ណោះ ចំនួន ៥០.៣ លានដុល្លារ។ |
| ៦. ការនាំចេញផលិតផលឈើកែច្នៃ | +៦៤៩% | +២៧២% | — |
| ៧.ការនាំចេញអង្ករ | +១២៣% | +៣៩៩% | — |

**កំណត់សម្គាល់៖**

-ព័ត៌មាន និងទិន្នន័យពណ៌ **បៃតង** សំដៅលទ្ធផលល្អប្រសើរ -ព័ត៌មាន និងទិន្នន័យពណ៌ **ក្រហម** សំដៅលទ្ធផលសម្រាប់ការប្រុងប្រយ័ត្ន

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/០៤/១១<br>ម៉ោង ០៩ : ០០ នាទី | ដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ស៊ិន ម៉េងស្រ៊ុន** ឯកឧត្តម **អ៊ុំ កុសល** និងឯកឧត្តម **កែវ វិចិត្រ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៤/០៤/១១<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមក្នុងកិច្ចប្រជុំចង្អៀត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើ៖<br>១-សំណើសុំការអនុម័ត លើគម្រោងប្លង់គោលរាជធានីភ្នំពេញឆ្នាំ២០២០។<br>២-បញ្ហាផ្សេងៗ។ |
| ៣ | ០៥/០៤/១១<br>ម៉ោង ០៩ : ០០ នាទី | ជាអធិបតីភាពក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ (Panorama Museum) ក្នុងខេត្តសៀមរាប រវាងអាជ្ញាធរអប្សរា និងក្រុមហ៊ុន Mansudae New Tech Corporation Ltd នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៥/០៤/១១<br>ម៉ោង ១០ : ០០ នាទី | ចូលរួមប្រជុំពិនិត្យការងារសាងសង់អគារលក់សំបុត្រពេលថ្ងៃ នៃមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរខេត្តសៀ រាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៦/០៤/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សាលាពិការភ្នែក និងកុមារគថ្លង់ ភ្នំពេញថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅផ្លូវហាណូយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ |
| ៦ | ០៦/០៤/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីយោធិនជាប់កិច្ចសន្យា។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១១ (បន្ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៧/០៤/១១<br>ម៉ោង ០៩ : ០០ នាទី<br>" | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្ដូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល។<br>២-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីយោធិនជាប់កិច្ចសន្យា។<br>៣-បញ្ហាផ្សេងៗ។ |
| ៨ | ០៧/០៤/១១<br>ម៉ោង ១៧ : ៣០នាទី" | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងរបស់ Far East Broadcasting Cambodia (FEB Cambodia) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |
| ៩ | ០៨/០៤/១១<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្ដីព្រាងគោលនយោបាយជាតិ ស្ដីពីការៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា ។<br>២-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិ សន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។<br>៣-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីប្រាក់ឧបត្ថម្ភវេនយាមប្រចាំការជូនមន្ត្រីរាជការ នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព។<br>៤-បញ្ហាផ្សេងៗ។ |
| ១០ | ១១/០៤/១១<br>ម៉ោង ០៩ : ០០ នាទី | ប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម អគ្គលេខាធិការ អគ្គលេខាធិការរង នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១២/០៤/១១<br>ម៉ោង ១៥ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសូត្រមន្តចំរើនព្រះបរិត្ត ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥ គ.ស. ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។ |
| ១២ | ១៣/០៤/១១<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមពិសារបាយសាមគ្គី ក្នុងឱកាសអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ឆ្នាំថោះ ត្រីស័ក ពុទ្ធសករាជ ២៥៥៥ នៅក្នុងបរិវេណទីស្ដីការគណៈរដ្ឋមន្ត្រី-ទីស្ដីការនាយករដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១១ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៣ | ២១/០៤/១១<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមក្នុងកិច្ចប្រជុំបង្កៀត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើ៖<br>១-សំណើសុំការអនុម័ត លើគម្រោងប្លង់គោលរាជធានីភ្នំពេញឆ្នាំ២០២០ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីប្លង់គោលតម្រង់ទិសអភិវឌ្ឍន៍រាជធានីភ្នំពេញ រហូតដល់ឆ្នាំ ២០២០ ។<br>២-បញ្ហាផ្សេងៗ។ |
| ១៤ | ២១/០៤/១១<br>ម៉ោង ១៥ : ៣០ នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៥ | ២៥/០៤/១១<br>ម៉ោង ១៥ : ០០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៦/០៤/១១<br>ម៉ោង ០៩ : ៣០នាទី | ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងលើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅបន្ទប់ឯកឧត្តមប្រធាន ECOSOCC។ |
| ១៧ | ២៨/០៤/១១<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីមីទ្ទីញអបអរសាទរខួបលើកទី ១២៥ ទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលកោះពេជ្រ។ |
| ១៨ | ២៨/០៤/១១<br>ម៉ោង ១៨ : ៣០នាទី" | ចូលរួមជាកិត្តិយសក្នុងពិធីរំលឹកខួបលើកទី ៧ នៃសមាជិកគណៈកម្មាការ ចិន ហុងកុង ម៉ាកាវ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់។ |

## សកម្មភាពដ៏ទៃទៀតរបស់ឯកឧត្តម យឹម ណុលសន
## អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៦/០៤/១១ | ចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារ វត្តទន្លេបាទី និងសម្ពោធអគារសិក្សាវិទ្យាល័យ សុខ អាន ទន្លេបាទី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តទន្លេបាទី ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។ |
| ២ | ១២/០៤/១១ | ចូលរួមជាកិត្តិយសក្នុងពិធីសូត្រមន្តចំរើនព្រះបរិត្ត ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥ គ.ស. ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២៨/០៤/១១ | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងខួបលើកទី១៥ នៃ DFDL MEKONG នៅ Raffles Hotel Le Royal ។ |

## សកម្មភាពដ៏ទៃទៀតរបស់ សមាជិក-សមាជិកា
## នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/០៣/១១ | ឯកឧត្តម **ទូច ចាន់ធី** ចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពី វិធានការហាមឃាត់ចំពោះការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ នៅក្រសួងព័ត៌មាន។ |
| ២ | ៣០/០៣/១១ | ឯកឧត្តម **ទូច ចាន់ធី** ចូលរួមកម្មវិធីសិក្ខាសាលាក្នុងតំបន់ស្តីពី ការពិនិត្យពាក់កណ្តាលគម្រោងរបស់ប្រទេសសម្រាប់លើកកម្ពស់មូលនិធិ និងការត្រួតពិនិត្យថ្នាំជក់ នៅទីក្រុងម៉ាឡាកា ប្រទេសម៉ាឡេស៊ី។ |
| ៣ | ០៧/០៤/១១ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារប្រចាំខែត្រីមាសទី១ ឆ្នាំ២០១១ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |



# ពិធីសូត្រមន្ត របស់ ECOSOCC



កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ នៅក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) នៃទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំពិធីសូត្រមន្តប្រសិទ្ធិពរជ័យសិរីមង្គលក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ ត្រីស័ក ពុទ្ធសករាជ ២៥៥៥ ក្រោមអធិបតីភាពឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC ដោយមានការអញ្ជើញចូលរួមពីសំណាក់ អនុប្រធាន សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ECOSOCC ព្រមទាំងមន្ត្រីនៃអគ្គ លេខាធិការដ្ឋានទាំងអស់៕

# ព្រឹត្តិបត្រព័ត៌មាន


នាយកគ្រប់គ្រងទូទៅ ៖ ឯកឧត្តម គីម ស៊ីសុផារ៉ាវណ្ណ អនុប្រធាន ក.ស.វ.

និពន្ធនាយក ៖ ឯកឧត្តម ថ្នា ភិរុណ អគ្គលេខាធិការ ក.ស.វ.

វិភាគស្ថានភាពសេដ្ឋកិច្ច៖ ឯកឧត្តម អ៊ឹម សាទ សមាជិកបម្រុង ក.ស.វ.

និពន្ធអក្ខរាវិរុទ្ធ ៖ ឯកឧត្តម ចេង ត្រឹមនី អគ្គលេខាធិការរង ក.ស.វ.

បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ លោក ស៊ុយ វាសនា ប្រធានការិយាល័យ ក.ស.វ.

ឃុកព័ត៌មាន និងថតរូប ៖ លោក ហេង ធុរៈចិន្ដា ប្រធានការិយាល័យ ក.ស.វ.

ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ លោក [illegible] ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក.ស.វ.




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in